# ការសំភាសន៍របស់លោកពូ សួន អួន

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍មាន សួន អួន

ការសង្ខេបប្រវត្តិរបស់ លោកពូ សួន អួន

លោកពូ សួន អួន មាន63អាយុឆ្នាំ នៅក្នុងឆ្នាំ2018 លោកពូ សួន អួន មានភេទប្រុស លោក សួន អួន មានទីលំនៅបច្ចុប្បន្ននៅ ភូមិព្រែកថ្លឹង សង្កាត់ជើងឯក ខ័ណ្ឌដង្កោ នៅរាជធានីភ្នំពេញ។

កៈ ចឹងជាដំបូងខ្ញុំអរគុណពូដែរបានអោយខ្ញុំពិភាក្សាជាមួយពូដែរទាក់ទងពីប្រវត្តិរបស់ពូ ហើយការសំភាសន៍ទាំងអស់នេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយៗអោយពួកគាត់ បានស្គាល់នឹងបានដឹងពីប្រវត្តិរបស់ឪពុកម្ដាយនឹង ប្រវត្តិរបស់ជូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍ពូ ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ពូហើយខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងសំរាប់ពូយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ដែរបានពិភាក្សាជាមួយតាទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរទេពូ?

ខៈ បាទៗៗ!!យល់ព្រម

កៈ បាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍ពូគឺនៅថ្ងៃទី25ខែ4 ឆ្នាំ2018 ហើយការសំភាសន៍ទាំងអស់នេះធ្វើឡើងនៅភូមិអីគេដែរពូ?

ខៈ នៅភូមិព្រែកថ្លឹង

កៈ ភូមិព្រែលថ្លឹង?

ខៈ នៅសង្កាត់ជើងឯក នៅខ័ណ្ឌដង្កោ នៅរាជធានីភ្នំពេញ

កៈ អ៊ូ!!បាទពូបាទ?

ខៈ បាទ!!

កៈ ចឹងសំរាប់ពូឈ្មោះពេញរបស់ពូមានឈ្មោះអីគេដែរពូ?

ខៈ បាទ!!ឈ្មោះខ្ញុំគឺឈ្មោះសួន អួន

កៈ ចុះមានឈ្មោះហៅក្រៅទេពូ?

ខៈ ហៅក្រៅខ្ញុំអត់មានទេមានតែឈ្មោះមួយនឹង

កៈ អ៊ូ!!

ខៈ ឈ្មោះតាំងពីដើមមកហើយនឹង

កៈ ចុះកាលពីក្មេងៗៗនឹងមានមិត្តភក្តិពូហៅពូអីផ្សេងដែរទេ?

ខៈ អត់មានទេក្មួយអត់មានទេហៅតែចឹងតែម្តង

កៈ អ៊ូ!!បាទពូ?

ខៈ តែឈ្មោះនៅក្នុងក្របខ័ណ្ឌរបស់ខ្ញុំនឹងខ្ញុំនិយាយការពិត

កៈ បាទ!!ពូបាទ?

ខៈ ការនៅសម័យសង្គមរាស្រ្តនិយាយឈ្មោះពិតនៅក្នុងក្របខ័ណ្ឌឈ្មោះសោម សារី

កៈ ឈ្មោះសោម សារី ប៉ុន្តែឈ្មោះសព្វថ្ងៃដែរពូប្រើជាប្រចាំនឹងពូមានឈ្មោះអីគេដែរ?

ខៈ ខ្ញុំឈ្មោះសួន អួន

កៈ ចឹងឈ្មោះ សួន អួនណា?

ខៈ បាទ!!ឈ្មោះសួន អួន ឈ្មោះសោម សារីនឹងឈ្មោះបុកជាមួយគ្រួសាររបស់ខ្ញុំពីមុន

កៈ បាទ!!ពូ?

ខៈ ចឹងដល់ពេលឈ្មោះរីដូចគ្នាគេតាមទំលាប់គេហៅណាស់ក្មួយណាស់

កៈ បាទ!!ប៉ុន្តែនៅក្នុងអត្តសញ្ញាណប័ណនឹងពូដាក់ឈ្មោះអីគេដែរពូ?

ខ៖ បាទ!!ខ្ញុំដាក់ឈ្មោះថាសួន អូន

ក៖ ចឹងហោសពូ?

ខ៖ បាទ!!ឈ្មោះសួន អូនបាទ

ក៖ បាទ!! ចុះសំរាប់ពូសព្វថ្ងៃនឹងពូអាយុប៉ុន្មានដែរពូ?

ខ៖ បាទ!!ខ្ញុំអាយុ63ឆ្នាំហើយក្មួយអាយុ63ឆ្នាំ

ក៖ អូ៎!!ពូកើតនៅថ្ងៃខែឆ្នាំណាពូមានចាំទេ?

ខ៖ ខ្ញុំកើតបើនិយាយតាមឆ្នាំសកលខ្ញុំកើតនៅឆ្នាំអានេះខ្ញុំមិនបានចាំថ្ងៃទេណាក្មួយណាស់

ក៖ បាទ!!ពូបាទ?

ខ៖ ថ្ងៃហើយនឹងខែនឹងមិនបានចាំទេនៅខែ10ប៉ុន្តែនៅឆ្នាំ1954

ក៖ អូ៎!!ពូចាំទាំងអស់ណាពូ?

ខ៖ បាទ!!បាទនៅឆ្នាំ1954

ក៖ ចុះសំរាប់ពូឆ្នាំច័ន្ទគតិឆ្នាំខ្មែរហោសពូ?

ខ៖ ឆ្នាំខ្មែរខ្ញុំកើតនៅឆ្នាំវក

ក៖ ចឹងពូកើតនៅឆ្នាំវកណាពូ?

ខ៖ បាទ!!នៅឆ្នាំវក

ក៖ ចុះពូកើតនៅណាដែរពូ?

ខ៖ ខ្ញុំកើតនៅកំណើតដែរខ្ញុំកើតនឹងនៅភូមិស្វាយតានី ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែក

ក៖ អូ៎!!ពូកើតនៅព្រៃវែងហោសពូ?

ខ៖ បាទៗ!!

ក៖ បាទ!!ចុះពូមានបងប្អូនចំនួនប៉ុន្មាននាក់ដែរពូសព្វថ្ងៃនឹងហាស?

ខ៖ បាទ!!ខ្ញុំមានបងប្អូនបង្កើតនឹងចំនួន8នាក់

កៈ ចុះពូជាកូនទីប៉ុន្មានដែរ?

ខៈ បាទ!!ខ្ញុំច្បងគេបង្អស់ជាកូនទី1ខ្ញុំ

កៈ ចុះពូមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរពូ?

ខៈ ខ្ញុំបើបងប្អូនរបស់ខ្ញុំមានប្រុស6នាក់ នឹងស្រី2នាក់ បាទ8នាក់ហាសក្មួយ

កៈ បាទ!!ពូបាទ ចុះពួកគាត់នៅរស់សព្វថ្ងៃទាំងអស់គ្នាមែនទេពូ?

ខៈ ស្លាប់ៗអស់មើលខ្ញុំគិតមើលសិន ស្លាប់អស់3នាក់ មើលនៅសល់

កៈ ចឹងនៅសល់5នាក់?

ខៈ មើលនៅសល់5នាក់បាទ

កៈ ចុះស្លាប់នឹងជាកូនទីប៉ុន្មានខ្លះដែរទៅពូ?

ខៈ ស្លាប់នឹងជាកូនទីបន្ទាប់ខ្ញុំនឹងបើតាមទំលាប់ខ្មែររបស់យើងនឹងជាកូនទី2ហាសក្មួយ

កៈ បាទ!!ពូបាទ?

ខៈ នឹងជាកូនទី2 ខ្ញុំជាកូនទី1នៅតាមទំលាប់ខ្មែរយើងនឹង

កៈ បាទ!!ពូបាទ?

ខៈ ស្លាប់ទី2 នឹងស្លាប់ទី3 ហើយនឹងស្លាប់ទី6

កៈ បាទ!!ពូបាទ?

ខៈ នឹងហើយស្លាប់កូនទី6

កៈ ចុះពូគិតថាប្អូនរបស់ពូទាំងអស់នឹងពូមានចងចាំឈ្មោះពួកគាត់ទាំងអស់ទេពូ?

ខៈ ខ្ញុំចាំបានទាំងអស់

កៈ ពួកគាត់មានឈ្មោះអីគេខ្លះដែរទៅពូ?

ខៈ បន្ទាប់ខ្ញុំមកខ្ញុំបើតាមក្របខ័ណ្ឌមកគេហៅសួន អួនណាស់

កៈ បាទ!!ពូបាទ?

ខ៖ ហើយបន្ទាប់ពីខ្ញុំមកឈ្មោះសួន សារុន

ក៖ អូ៎!!ប៉ុន្តែដាក់ឈ្មោះសួនទាំងអស់នឹងតែហោសពូ?

ខ៖ បាទ!!ដាក់ឈ្មោះសួនទាំងអស់ បាទសួនទាំងអស់ត្រកូលហាស

ក៖ បាទ!!ពូបាទ?

ខ៖ ដាក់ជាមួយគ្នា

ក៖ ចុះបន្ទាប់មកទៀតពូ?

ខ៖ ឈ្មោះសួន សារុន ហើយបានឈ្មោះសួន សារឿន

ក៖ ហើយបន្ទាប់មកទៀតពូ?

ខ៖ ឈ្មោះសួន សារឿនហើយបានមកឈ្មោះសួន សារឹម ឈ្មោះសួន សារឹម ហើយបានឈ្មោះសួន គឹមហួនណាស់

ក៖ បាទ!!ពូបាទ?

ខ៖ ឈ្មោះ សួន គឹមហួននឹងស្រី សួនគឹមហួននឹងស្រី បានបន្ទាប់មកទៀតឈ្មោះសួន សារុំ ឈ្មោះសួន សារ៉ា ហើយនឹងឈ្មោះសួន ហឿន

ក៖ នឹងពៅគេហោសពូ?

ខ៖ នឹងពៅគេបង្អស់ហាសស្រីហាស

ក៖ បាទ!!ហើយចុះពូដូចជាពូធ្លាប់មានអនុស្សាវរីយ៍អីជាមួយប្អូនៗរបស់ពូកាលពីពូនៅក្មេងជាមួយគាត់ ដែរទេធ្លាប់លេងអីគេខ្លះជាមួយគ្នាចឹងហាស

ខ៖ កាលនៅក្មេងនឹងក្មួយខ្ញុំនឹងជាកសិករ

ក៖ បាទ!!ពូបាទ?

ខ៖ នៅខាងស្រុកស្រែអើរយើងនៅស្រុកស្រែណាស់

ក៖ បាទ!!ពូបាទ?

ខ៖ យើងធ្វើតែស្រូវនាំបងប្អូននឹងទៅនឹងនាំគ្នាជួយធ្វើការឪពុកម្ដាយ ឃ្វាលក្របីឃ្វាលអីចឹងទៅ ដើរជួយស្ទូងដក រកត្រីសាច់អីឧបត្ថមគ្រួសារប្រចាំថ្ងៃចឹងណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ត្រូវការស្ទូងដកទេក្មួយ នៅស្រុកស្រែគ្មានអីក្រៅពីស្ទូងដកទេ

ក៖ បាទ!!ពូបាទ?

ខ៖ ដល់រដូវធ្វើស្រែ ហើយបើខែប្រាំយើងចេញទៅឃ្វាលក្របី ហើយយកក្របីទៅធ្វើរោងធ្វើអីទៅខាង ទន្លេហាសគេហៅទន្លេខ្សាច់សរហាសក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!ទន្លេសាច់សរហាសយើងយកក្របីទៅឃ្វាលខាងទន្លេនឹងវាមានទឹក វាមានស្មៅចឹងទៅមាន អូសចឹងរកត្រីរកសាច់ចឹងទៅ កាប់អូសកាប់អីដល់ខែវស្សាយើងដឹកអូសដឹកអីទៅផ្ទះណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ដឹកទៅផ្ទះបាទ

ក៖ ចុះពូ?

ខ៖ បានពីនឹងទៅយើងគិតថាគិតគូតែពីរឿងអូសនឹងហើយបាទ

ក៖ បាទ!!ចុះសំរាប់ពូគិតថាសំប្អូនៗរបស់ពូសព្វថ្ងៃគាត់នៅណាដែរពូ?

ខ៖ ប្អូនៗអានឹងយើងកុំនិយាយពីអ្នកស្លាប់ណាក្មួយ

ក៖ បាទៗ!!ពូ?

ខ៖ យើងនិយាយសំរាប់អ្នកដែររស់

ក៖ គាត់នៅណាដែរពូ?

ខ៖ អ្នករស់ខ្លះទៅក៏ទៅនៅខាងមណ្ឌលគិរី ដើម្បីរកទៅហូបចុកនៅណុងណាស់ក្មួយ

កៈ បាទ!!ពូបាទ?

ខៈ បច្ចុប្បន្ននឹងហាសនៅខាងមណ្ឌលគិរីហោស

កៈ បាទ!!ពូ?

ខៈ ប៉ុន្តែមីប្អូនពៅមួយទៅធ្វើការនៅពោធ៍ចិនតុងនឹងហាស

កៈ បាទ!!ពូបាទ?

ខៈ ធ្វើការងារនៅរោងចក្រកាត់ដេរហាសក្មួយ

កៈ បាទ!!ចុះអ្នកនៅមណ្ឌលគិរីនឹងគេធ្វើអីគេដែរពូ?

ខៈ ទៅខាងនឹងគេច្រើនប្រកបមុខរបរ

កៈ ធ្វើស្រែចំការហីពូ?

ខៈ ទេជីករណ្តៅដូចថាជីករករ៉ែមាសអីនឹងហាសក្មួយ

កៈ អូ៎!!បាទពូបាទ?

ខៈ នឹងធ្វើមុខរបរនឹង

កៈ ចុះសំរាប់ម្តាយរបស់ពូនឹងគាត់មានឈ្មោះអីគេដែរពូ?

ខៈ ម្តាយរបស់ខ្ញុំនឹងមានឈ្មោះចាន់ លន់

កៈ ប៉ុន្តែគាត់សព្វថ្ងៃនឹងគាត់អាយុប៉ុន្មានដែរពូ?

ខៈ គាត់អាយុ80ឆ្នាំគត់ហើយ

កៈ ចឹងអាយុ80ឆ្នាំគត់ណាពូ?

ខៈ បាទ!!អាយុ80គត់នឹងហាស

កៈ ប៉ុន្តែគាត់កើតនៅណាដែរពូ?

ខៈ កំណើតកើតរបស់គាត់នឹងដូចខ្ញុំនិយាយថានៅភូមិស្វាយតានី ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែងនឹងហាសក្មួយ

កៈ បាទ!!ពូប៉ុន្តែដូចជាឪពុករបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខៈ ឪពុករបស់ខ្ញុំនឹងឈ្មោះសោម ប្រាជ

កៈ ចុះគាត់ដល់ប្រហែលឥឡូវនឹងគាត់ប្រហែលជាអាយុប៉ុន្មានដែរពូមានដឹងទេ?

ខៈ គាត់នឹងប្រហែលមើលម្តាយរបស់ខ្ញុំនឹងអាយុ80ឆ្នាំគិតមកទល់ឥឡូវនឹងហាស

កៈ បាទ!!ពូបាទ?

ខៈ គិតមកទល់ឥឡូវនឹងក៏គាត់បងម្តាយរបស់ខ្ញុំមួយទប់បងមួយជួរ12ឆ្នាំក៏

កៈ ចឹងវាអាយុ92ឆ្នាំ?

ខៈ បាទ!!វាអាយុកៅជាងហើយ

កៈ បាទ!!ពូបាទ?

ខៈ បាទ!!គាត់កៅជាងហើយនឹង

កៈ ចុះឪពុករបស់ពូសព្វថ្ងៃគាត់នៅណាដែរពូ?

ខៈ គាត់ស្លាប់ហើយ

កៈ អូ៎!!គាត់ស្លាប់ហើយណពូ?

ខៈ ពីព្រោះឪពុករបស់ខ្ញុំធ្វើជាទាហ៊ានបីជំនាន់

កៈ អូ៎!!ច្រើនហាសណពូណា?

ខៈ បាទ!!ធ្វើជាទាហ៊ានបីជំនាន់

កៈ ចុះឪពុករបស់ពូគាត់កើតនៅណាពូមានដឹងទេ?

ខៈ
គាត់កើតនៅនឹងនៅភូមិជាមួយគ្នានឹងម្តាយរបស់ខ្ញុំនឹងឪពុករបស់ខ្ញុំនឹងកើតនៅភូមិជាមួយគ្នានឹងក្មួយ

កៈ បាទ!!ពូបាទ?

ខ៖ នៅភូមិជាមួយគ្នានឹង

ក៖ ចុះពូគិតថាឪពុករបស់ពូកាលពីគាត់នៅរស់គាត់ធ្វើអីគេសំរាប់ចិញ្ចឹមជិវិតដែរពូ?

ខ៖
ចិញ្ចឹមជីវិតនឹងបានម្តាយរបស់ខ្ញុំមកនឹងគាត់ធ្វើតែស្រែតែមុនបានម្តាយរបស់ខ្ញុំនឹងគាត់ធ្វើទាហ៊ាន ជំនាន់បារាំងហាស

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!គាត់ធ្វើទាហ៊ានបារាំង

ក៖ អូ៎!!ចុះឪពុករបស់ពូដូចជាគាត់ស្លូតរឺមួយក៏គាត់កាចដែរពូ?

ខ៖ ឪពុករបស់ខ្ញុំគាត់ស្លូតតើក្មួយចរឹករបស់គាត់ស្លូតទេគាត់មិនកាចទេ

ក៖ អូ៎!!បាទពូ?

ខ៖ គាត់កាចនឹងគាត់កាចមានសណ្ឋានរបស់គាត់ដូចថាយើងខុសខ្លាំងចឹងទៅ
រឺមួយក៏យើងធ្វើអ្វីមួយដែរ ខុសខ្លាំងនឹងបានគាត់ស្តីបន្ទោសយើងនឹងហាស

ក៖
បាទ!!ពូបាទចុះសំរាប់ដូចជាម្តាយរបស់ពូពីមុនគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតនឹងចិញ្ចឹមក្រុមគ្រួសារ ដែរចឹងហាសពូ?

ខ៖ ធ្វើស្រែក្មួយគ្មានអីក្រៅពីធ្វើស្រែទេហើយនឹងលក់ដូរបន្តិចបន្តួច
គាត់លក់ផ្សេងៗជាគ្រឿងបន្លែ បន្តកមានត្រី សាច់នឹងហើយ

ក៖ បាទ!!ពូបាទ?

ខ៖ ដើម្បីចិញ្ចឹមជីវិតប្រចាំថ្ងៃហាសក្មួយ

ក៖ បាទ!!ពូបាទ ចុះសំរាប់ម្តាយរបស់ពូគាត់ស្លូត រឺមួយក៏គាត់កាចដែរពូ?

ខ៖ គាត់ស្លូតឪពុកម្តាយរបស់ខ្ញុំនឹងគាត់ស្លូតទាំងពីរ

ក៖ បាទ!!ពូ?

ខ៖
ដូចក្មួយឃើញស្រាប់ហើយក្មួយស្រីកំពុងតែសំភាសន៍ហើយនឹងម្តាយរបស់ខ្ញុំហើយនឹងហាស

ក៖
បាទ!!បាទពូចុះដូចជាពូមានចងចាំថាកាលពីពូនៅជាមួយឪពុកម្តាយរបស់ពូកាលពីពូនៅក្មេងៗៗ ហាសពូធ្លាប់មានអនុស្សាវរីយ៍អីធ្វើស្រែចំការ
រឺធ្វើដើរលេងជាមួយឪពុកម្តាយរបស់ពុដែរចាំអត់ភ្លេចទេពូ?

ខ៖ ខ្ញុំនៅពេលដែរខ្ញុំនៅប្រហែលជាអាយុខ្ញុំស្មានហាសក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ខ្ញុំស្មានតែប្រហែលជាអាយុ8-9ឆ្នាំពេលរដូវធ្វើស្រែអីចឹង
ឪពុកម្តាយរបស់ខ្ញុំគាត់ធ្វើស្រែហើយចឹងទៅ
ប្រមូលផលបានទុកដាក់ស្រួលបួលចឹងហើយទៅ
ឪពុករបស់ខ្ញុំច្រើនសុំលាគ្រួសារនឹងទៅរកហូបចុក ធ្វើកម្មករគេនោះនៅខាងអូររាំងឪ

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!ទៅធ្វើកម្មករនៅអូររាំងឪទៅលីប៉ាវនៅរោងចក្រម៉ាស៊ីនស្រូវណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ លីប៉ាវស្រូវលីប៉ាវអង្ករអីនៅខាងផ្សារអូររាំងឪនឹងហាស

ក៖ បាទ!!ពូបាទ?

ខ៖ គាត់ទៅនឹង

ក៖
ចុះសំរាប់ឪពុករបស់ពូកាលពីគាត់នៅក្មេងនឹងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិអីនៅក្មេងទៅពូដែរទេ?

ខ៖
ប្រវត្តិរបស់គាត់នឹងប្រវត្តិរបស់ខ្ញុំតាមដឹងឪពុករបស់ខ្ញុំនឹងគាត់ធ្វើទាហ៊ានមុនដំបូងដែរមិន

ទាន់
បានម្តាយរបស់ខ្ញុំនឹងគាត់ការគាត់ការជាមួយបងប្អូនជីដូនមួយគាត់ប៉ុន្តែគាត់អត់ស្រលាញ់ទេណាស់

ក៖ បាទ!!ពូបាទ?

ខ៖
គាត់អត់ស្រលាញ់ទេឪពុកគាត់ដូចថាឪពុកម្តាយនឹងបង្ខំអោយការជាមួយបងប្អូនជីដូនមួយចឹងទៅ

ក៖ បាទ!!ពូ?

ខ៖ ដល់ចឹងគាត់ក៏អត់ស្រលាញ់គាត់ក៏រត់ទៅធ្វើជាទាហ៊ាន
បាទអានឹងទាហ៊ានកាលពីជំនាន់បារាំងណាក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖
គេអោយគាត់ទៅធ្វើទាហ៊ាននឹងគេអោយគាត់នឹងទៅឈរជើងនៅខេត្តកំពង់ធំនឹងគាត់ក៏មាន គ្រួសារនឹងមួយទៀតមានគ្រួសារនៅនឹងមួយទៀតហាស

ក៖ បាទ!!ផពូបាទ?

ខ៖ បានកូនមួយបងខ្ញុំនឹងប៉ុន្តែគ្រាន់តែថាឪពុកតែមួយនឹងម្តាយដោយខ្លួន

ក៖ បាទ!!ពូបាទ?

ខ៖ គាត់ធ្វើរួចទៅគាត់វិលត្រលប់មកផ្ទះវិគាត់និយាយប្រាប់ខ្ញុំហាសក្មួយ

ក៖ បាទ!!ពូបាទត្រូវ?

ខ៖
បាទ!!ត្រលប់មកវិញចឹងទៅគាត់មកដល់ផ្ទះវិញចឹងទៅគាត់ក៏ចេញពីទាហ៊ានចឹងទៅគាត់ត្រលប់មក
ផ្ទះវិញនឹងជីដតារបស់ខ្ញុំនឹងបានស្តីដណ្តឹងម្តាយរបស់ខ្ញុំសព្វថ្ងៃនឹងហាសអោយគាត់ហា
ហើយបានគា្មរហូតទាល់តែសម័យពលពតនឹងបាន

សម័យពលពតនឹងបានគេចាប់គាត់ដាក់ក្នុងពន្ធ
ធានាគារហាសគាត់បានស្លាប់នៅក្នុងពន្ធធានាគារឪពុករបស់ខ្ញុំនឹង

ក៖ អូ៎!!ចឹងហោសពូ?

ខ៖ ប្រវត្តិទាហ៊ានគាត់ធ្វើទាហ៊ានពីរជំនាន់
ជំនាន់មួយជំនាន់ហើយមកដល់ជំនាន់លុនណុលនឹងក៏គាត់
មកធ្វើទៀតបានធ្វើទៀតដល់ពេលចឹងទៅគេដឹងពីជីវប្រវត្តិចឹងទៅគាត់ចាប់គាត់ដាក់ក្នុងព
ន្ធធានាគារនឹង គាត់បានស្លាប់នៅក្នុងពន្ធធានាគារនឹងក្មួយ

ក៖ អូ៎!!ស្លាប់ដោយសារតែអត់បាយរឺមួយយ៉ាងម៉េចដែរពូ?

ខ៖
ស្លាប់បើខ្ញុំសើបសួរតាមពួកម៉ាក់គាត់នឹងទៅដែរនៅជាមួយគាត់ហើយគាត់បានរស់រានរហូ
តមកដល់ សព្វថ្ងៃដែរខ្ញុំបានសួរគាត់ហាស

ក៖ បាទ!!ពូបាទ?

ខ៖
ថាដាក់នឹងគេដាក់នៅក្នុងពន្ធធានាគារនឹងគេដាក់ខ្នះនៅក្នុងគុកនឹងហើយគាត់ក៏មានជំងឺ
ឈឺរាគមួល

ក៖ បាទ!!

ខ៖ បាទ!!ហើយអត់មានថ្នាំសង្កូវអីមកព្យាបាលទេ
ម៉្យាងទៀតនឹងហូបចុកនឹងក៏ខ្វះខាតគ្រប់បែបយ៉ាង ក៏គាត់ឈឺស្លាប់បាត់ទៅ

ក៖ អូ៎!!បាទពូបាទ?

ខ៖ គាត់ក៏ស្លាប់បាត់ទៅក្មួយ

ក៖ បាទ!!ចុះម្ដាយរបស់ពូវិញគាត់មានដែរប្រាប់ពីប្រវត្តិទេពូ?

ខ៖
ម្ដាយខ្ញុំទាល់គេចាប់ឪពុកខ្ញុំនៅសម័យនឹងគេចាប់ឪពុករបស់ខ្ញុំទៅដាក់ក្នុងពន្ធធានាគារចឹង
ទៅ ហើយម្ដាយរបស់ខ្ញុំនឹងក៏គាត់ទ្រុឌទ្រោមសុខភាពដែរសព្វថ្ងៃនឹងហាស

កៈ បាទ‼ពូ?

ខៈ គាត់ទ្រុឌទ្រោមសុខភាពសរសៃរជើងសរសៃរដៃដែរនឹង
ដោយសារតែយ៉ាងម៉េចដោយសារតែ កាលពណុងគេសំរឹទ្ធិសំរាងហាស

កៈ បាទៗ‼ពូ?

ខៈ ប្រពន្ធទាហ៊ានចឹងគេសំរិទ្ធិសំរាងគេអោយគាត់ភ្ជួរ

កៈ បាទ‼ពូបាទ?

ខៈ បាទ‼គេអោយឡើងទៅភ្ជួរជាមួយពួកកងចល័តនឹងតាំងពីម៉ោង10-
11នឹងឡើងទៅភ្ជួររហូតទាល់តែ ទៅដល់ម៉ោង10-
11ថ្ងៃបានគេឈប់អោយភ្ជួរជាមួយប្រុសៗនឹងក្មួយ

កៈ បាទ‼ពូបាទ?

ខៈ នឹងហើយចំណែកប្រពន្ធទាហ៊ានគេធ្វើបាបខ្លាំងមែនទែនក្មួយកាលណុង

កៈ អូ៎‼បាទចុះដូចជាយាយតាខាងឪពុកពូមានស្គាល់ឈ្មោះទេពូ?

ខៈ ចាំអាចនឹងចាំពីព្រោះជីតាខាងឪពុកខ្ញុំនឹងអាចទាន់ហាសក្មួយ

កៈ គាត់មានឈ្មោះអីគេដែរទៅពូ?

ខៈ បាទ‼ឪពុករបស់ខ្ញុំជីតាខាងឪពុករបស់ខ្ញុំនឹងមានឈ្មោះតា ម៉ម សោម

កៈ ប៉ុន្តែចុះយាយ?

ខៈ យាយឈ្មោះឈិន ឈ្មោះយាយឈិន ប៉ុន្តែរបស់គាត់ខ្ញុំអត់ចាំត្រកូលរបស់គាត់ហាស

កៈ បាទ‼ពូបាទ?

ខៈ អត់ចាំទេ

កៈ ចុះយាយតាខាងម្តាយវិញពូ?

ខៈ តាខាងម្តាយនឹងឈ្មោះណាចាន់ សួន

កៈ ចុះខាងម្តាយយាយវិញ?

ខៈ ហើយយាយៗខាងប្រពន្ធគាត់នឹងឈ្មោះ វ៉ា ហោង

កៈ ប៉ុន្តែមានដឹងថាយាយតាខាងឪពុកនឹងគាត់នៅណាដែរទេពូ?

ខៈ
គិតទៅម៉ាពូជពងវង្សត្រកូលកំណើតជីដូនជីតារបស់ខ្ញុំទាំងអស់នឹងគឺនៅភូមិជាមួយគ្នាទាំងអស់ក្មួយ

កៈ អូ៎!!

ខៈ គឺនៅភូមិព្រែកតានៅ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែងទាំងអស់នឹង

កៈ ទាំងយាយតាខាងឪពុកទាំងយាយតាខាងម្តាយ?

ខៈ បាទ!!ទាំងអស់នឹងទាំងខាងម្តាយនឹងអត់មាននៅក្រៅទេ នៅភូមិជិតគ្នាទាំងអស់នឹង

កៈ បាទ!!ពូមករស់នៅនឹងយូរនៅពូ?

ខៈ ខ្ញុំមករស់នៅព្រែកថ្លឹងតាំងពីឆ្នាំ1998ហាសក្មួយ

កៈ ចឹងហោសពូ?

ខៈ តាំងពីឆ្នាំ1998បោះឆ្នោតហើយនឹងខ្ញុំចេញមកតែម្តង

កៈ អូ៎!!បាទពូ?

ខៈ ចេញមកដល់ហូបចុកនៅណុងតែម្តងនឹង

កៈ ប៉ុន្តែពូមានបងប្អូនរឺមួយក៏កូនចៅដែរទៅរស់នៅក្រៅប្រទេសទេពូ?

ខៈ អត់ក្មួយអត់ទេអត់មានទេ

កៈ ទៅនៅថៃទៅធ្វើការអីក៏អត់មានដែរណាពូ?

ខៈ អត់ទេមានតែក្មួយៗទៅនៅថៃសព្វថ្ងៃនឹងហាស

កៈ ចុះពួកគាត់ធ្វើអីគេដែរនៅថៃនឹងពូ?

ខៈ ក្មួយរបស់ខ្ញុំនៅថៃនឹងក្មួយខ្ញុំធ្វើខាងសំណង់ទាំងអស់ក្មួយធ្វើខាងសំណង់ទាំងអស់នឹង

កៈ លក្ខណៈថាជាពលករនឹងហោសពូ?

ខៈ បាទ!!ពលករនឹង

កៈ អូ៎!!បាទ ចុះពូគិតថាភរិយារបស់ពូមានឈ្មោះអីគេដែរពូ?

ខៈ ភរិយាមុនរឺមួយក៏ភរិយាក្រោយក្មួយ

កៈ អាចភរិយាក្រោយហាសពូ?

ខៈ ភរិយាក្រោយគាត់មានឈ្មោះអេីរ ខុន សុខំ

កៈ ចុះពូមានចងចាំថាពូបានរៀបអាពាហ៍ពិពាហ៍នៅថ្ងៃខែឆ្នាំណាដែរទេពូ?

ខៈ ខ្ញុំនឹងទើបតែរៀបដែរប៉ុន្តែដូចជាមានការភ្លេច
ខ្ញុំភ្លេចហើយក្មួយមើលខ្ញុំរៀបគ្រួសារខ្ញុំមុននឹងស្លាប់
ខ្ញុំរៀបបាន6ខែហើយនេះក្មួយនឹងបាន6ខែទេនឹង

កៈ អូ៎!!ទើបតែ6ខែថ្មីៗៗនឹងទេណាពូ?

ខៈ បាទ!!បាទ6ខែនឹងទើបតែរៀប

កៈ ចុះបើភរិយាពូមុននឹងរៀបបានប៉ុន្មានឆ្នាំដែរហើយ?

ខៈ យូរៗៗហើយខ្ញុំរៀបជាមួយភរិយាខ្ញុំមុនតាំងពីជំនាន់ពលពតនឹងហើយ

កៈ អូ៎!!

ខៈ តាំងពីឆ្នាំ1978នឹងក្មួយ

កៈ បាទ!!ពូបាទ?

ខៈ នៅឆ្នាំ1978ខ្ញុំបានរៀបជាមួយប្រពន្ធរបស់ខ្ញុំមុននឹង

កៈ ចុះលក្ខណៈថាប្រពន្ធក្រោយរបស់ពូនឹង
តើពូគិតថាពូរៀបចំដោយចិត្តឯងរឺក៏ឪពុកម្តាយជាអ្នករៀបចំអោយដែរពូ?

ខៈ អានេះខ្ញុំវារើសដោយខ្លួនឯង

ក៖ អូ៎!!បាទ?

ខ៖ ខ្ញុំត្រូវចិត្តខ្លួនឯងតែស្របឪពុកម្ដាយ

ក៖ ចឹងឪពុកម្ដាយគាត់ក៏ជាអ្នកស្របជាមួយដែរ?

ខ៖ នឹងឪពុកម្ដាយគាត់ក៏ជាអ្នកស្របជាមួយយើងដែរណាក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖

យល់ស្របជាមួយគ្នាបងប្អូនកូននឹងក៏ឯកភាពស្របមកជាមួយគ្នាដែរនឹងហាសក៏រៀបចំគាត់នឹងទៅ

ក៖ បាទ!!ចុះដូចជាមីងស្គាល់ពូដោយរបៀបម៉េចដែរពូ?

ខ៖ ស្គាល់មីងក្រោយនឹងហោយក្មួយ?

ក៖ បាទៗ!!ពូបាទ

ខ៖ ស្គាល់នឹងគាត់ជាមិត្តភក្តិរបស់គ្រួសាររបស់ខ្ញុំមុនមិត្តភក្តិណាស់

ក៖ អូ៎!!បាទពូបាទ?

ខ៖ ហើយគាត់ក៏ឧស្សាហ៍មកលេងផ្ទះរបស់ខ្ញុំទៅកាលពីគ្រួសាររបស់ខ្ញុំនៅរស់នឹងហាស

ក៖ បាទៗ!!ពូបាទ?

ខ៖ នៅរស់ចឹងទៅគាត់មកចឹងទៅរួចក៏ចៃដន្យគ្រួសារខ្ញុំមុនស្លាប់បាត់ទៅ ខ្ញុំក៏នឹកឃើញគាត់នៅជាមួយគេ គាត់អត់មានឪពុកម្ដាយទេ

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!គាត់នៅជាមួយគេ ហើយឪពុកក៏អត់ម្ដាយក៏អត់កូនក៏អត់គាត់នៅក្រមុំចាស់ ហើយដល់ប្រពន្ធរបស់ខ្ញុំស្លាប់ទៅខ្ញុំនឹកឃើញអាណិតគាត់ខ្ញុំក៏យកមកទៅគិតគូរៀបចំទៅអោយមកនៅជាមួយក្រុមគ្រួសារខ្ញុំទៅ

ក៖ បាទ!!ពូ?

ខ៖ បាទ!!រហូតមកដល់សព្វថ្ងៃនឹងទៅ

ក៖ បាទ!!ដូចជាពូធ្លាប់បានរៀនអក្សរខ្មែរដែរទេពូ?

ខ៖ ខ្ញុំទៅករៀននៅសម័យសង្គមរាស្ត្រនិយមហាសក្មួយខ្ញុំរៀនបានតិចណាស់

ក៖ រៀនបានថ្នាក់ទីប៉ុន្មានទៅពូ?

ខ៖ រៀនបានត្រឹមថ្នាក់ទី10នៅសង្គមចាស់ហាសក្មួយ

ក៖ អូ!!បាទចុះពូពេលណុងពូបានរៀនភាសាអីផ្សេងទេពូ?

ខ៖
អត់មានទេក្មួយគ្រាន់តែយើងរៀនបានថ្នាក់ទី10គ្រាន់តែស្គាល់ស្រះបារាំងបន្តិចបន្តួចណាស់ក្មួយ

ក៖ បាទ!!ពូ?

ខ៖
គ្រាន់តែបានស្គាល់ស្រះបារាំងបន្តិចបន្តួចនឹងហាសក្មួយគ្រាន់តែប្រកបចេញជាពាក្យបន្តិចបន្តួចនៅ ឡើយទេស្រះបារាំងបន្តិចបន្តួចត្រឹមថ្នាក់ទី10ណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ត្រឹមថ្នាក់ទី10សម័យសង្គមរាស្ត្រនិយមនឹងប៉ុណ្ណឹង

ក៖ បាទ!!ពូចុះពូគិតថាកាលពីពូរៀននឹងពូរៀននៅណាដែរពូ?

ខ៖ ខ្ញុំកន្លែងខ្ញុំរៀននៅសាលាវត្តព្រះស្រែនឹង សង្កាត់បឹងព្រះ នៅស្រុកបាភ្នំ ខេត្តព្រៃវែងនឹងណាក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!នៅសាលាវត្តព្រះស្រែនឹង

ក៖ ចុះពូគិតថាកាលពីពូរៀននឹងពូធ្លាប់មានមិត្តភក្តិដែរធំធាត់មកជាមួយគ្នាដែរទេពូ?

ខ៖ មានក្មួយមានមិត្តភក្តិរបស់ខ្ញុំនឹង

ក៖ ប៉ុន្តែពូមានច្រើនទេពូ?

ខ៖
មិត្តភក្តិរបស់ខ្ញុំនៅក្នុងសាលាមិនមានច្រើនទេមិត្តដែរស្រលាញ់គ្នានឹងត្រឹមពីរទៅបីនាក់ប៉ុណ្ណឹងក្មួយ

ក៖ អូ៎!!បាទពូ?

ខ៖ បាទ!!

ក៖ ប៉ុន្តែពូអាចប្រាប់ឈ្មោះពួកគាត់មានទេថាពួកគាត់មានឈ្មោះអីចឹងហាសពូ?

ខ៖ អើរមិត្តភក្តិរបស់ខ្ញុំមួយមានឈ្មោះឡាច សុខន ហើយទីពីរនឹងមានឈ្មោះវណ្ណ អន ហើយទីបីនឹងមានឈ្មោះខន នឹងពីរនាក់ណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ប៉ុន្តែត្រកូលខុសគ្នា ឡាច សុខន មួយនឹងឈ្មោះឃី សុខននឹងមួយ បាទហើយនឹងវណ្ណ អននឹងបីរ មានប៉ុណ្ណឹងមិត្តភក្តិដែរស្រលាញ់គ្នារៀនជាមួយគ្នាណាស់ក្មួយ

ក៖ បាទ!!ពូបាទ ចុះពូគិតថាពូធ្លាប់មានអនុស្សាវរីយ៍អីជាមួយគ្នាដែរទេ ធ្លាប់លេងអីជាមួយគ្នាដែរទេ?

ខ៖ មានដែរតើក្មួយ

ក៖ ពេលណុងពូបានធ្វើអីគេខ្លះដែរទៅពូ?

ខ៖ លេងអីនឹងមានលេងបាល់លេងអីជាមួយគ្នាចឹងទៅណាស់ លេងនឹងមានបាល់ទាល់បាល់ទះអីជាមួយគ្នានឹងហាស

ក៖ បាទ!!ពូបាទ?

ខ៖ ហើយនឹងក៏បានទៅជិះទូងជិះអីនៅក្នុងសាលាហាសក្មួយកាលនឹង

ក៖ អូ៎!!បាទពូ កាលពីជំនាន់ពូនឹងមានបាល់ទាល់បាល់ទះដែរហោសពូ

ខ៖
មានតើក្មួយមានបាទបាល់ទាល់លោកគ្រូៗមានកន្លែងអោយយើងមានកន្លែងបាល់ទាល់នឹង បាល់ទះណាស់ក្មួយណាស់

ក៖ អូ៎!!បាទពូ?

ខ៖ កាលណុងកាលនៅជំនាន់នៅសកពាក់ខោអាវយោយវ៉ាន់ណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ នៅពាក់ខោអាវយោយវ៉ាន់ហាស

ក៖
បាទ!!ចុះពូតាំងពីក្មេងរហូតមកដល់ពេលនេះតើពូគិតថាពូធ្លាប់បានធ្វើការងារអីគេខ្លះដែរពូ?

ខ៖
ខ្ញុំកន្លងមកខ្ញុំនៅសម័យសង្គមមុនខ្ញុំនិយាយត្រង់កាលពីសម័យសង្គមសម័យប្រជាជាតិនោះ

ក៖ បាទ!!ពូបាទ?

ខ៖ ចូលធ្វើនៅខាងណែនេះហាសខាងម៉ាស៊ីនស្រូវហាស

ក៖ បាទ!!ពូ?

ខ៖ នៅខាងផលិតម៉ាស៊ីនស្រូវជំនាន់ពលពតនឹងធ្វើខាងម៉ាស៊ីនស្រូវនឹង

ក៖ បាទ!!ពូបាទ?

ខ៖ ខាងម៉ាស៊ីនស្រូវខាងសំរាប់យើងដឹកជញ្ជូនស្រូវ
នឹងជញ្ជូនអង្ករអោយខាងកងចល័តហូបនឹងណាស់ក្មួយណាស់

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!គេចាប់តាំងអោយយើងធ្វើចឹង

ក៖ ចុះពូគិតថាពូធ្លាប់ទៅធ្វើស្រែដែរមែនទេពូ?

ខ៖ ធ្វើស្រែនៅសម័យពលពតនឹងជូនកាលដកកំលាំងចល័ត
ឧទាហរណ៍អោយយើងដឹកជញ្ជូនអង្ករចឹង
ទៅចែកកងចល័តចឹងទៅដូរយើងអោយមកស្ទូងដកចឹង

ក៖ អ៎ូ!!

ខ៖ ក៏ខ្ញុំធ្លាប់ទៅស្ទូងដកនៅក្នុងកងចល័តនឹងដែរក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ស្ទូងដកក៏ធ្លាប់ដែរ

ក៖ ចុះពូគិតថាពូធ្លាប់បើកអាជីវកម្មលក់ដូររឺមួយក៏ចិញ្ចឹមសត្វចិញ្ចឹមអីទេពូ?

ខ៖ ដល់ក្រោយបន្ទាប់មកពីសម័យពលពតមកនឹងហាសក្មួយហាស

ក៖ បាទ!!ពូបាទ?

ខ៖ បន្ទាប់ពីសម័យពលពតមកនឹងខ្ញុំប្រកបអាជីវកម្មដើរលក់ដូរក្មួយអើយកំសត់កំរណាស់
នៅក្នុងឆាកជីវិតរបស់ខ្ញុំនឹង

ក៖ ប៉ុន្តែពូមានធ្លាប់ចិញ្ចឹមសត្វអត់ពូ?

ខ៖ សត្វនឹងចិញ្ចឹមក្មួយចិញ្ចឹម ចិញ្ចឹមមាន់អីទៅតាមលក្ខណះគ្រួសារហាស

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!តាមលក្ខណះគ្រួសារ មានមេបួនប្រាំចឹងទៅ មានមាន់ មានទា
មានជ្រូកអីជាធម្មតាចឹងទៅជា លក្ខណះគ្រួសារចឹងធ្លាប់ចិញ្ចឹម

ក៖ បាទ!!ពូ?

ខ៖ បាទ!!ធ្លាប់ចិញ្ចឹម

ក៖ ប៉ុន្តែពូគិតថាពូមានធ្លាប់ជួបការលំបាកអីគេខ្លះនៅក្នុងជីវិតរបស់ពូដែរចឹងហាសពូ?

ខ៖ លំបាកណាស់ក្មួយលំបាកណាស់ទើបអារឹកពីបែកសម័យពលពតហើយ
អើរអានឹងយើងនិយាយពីត្រលប់មកក្រោយវិញរឺនិយាយទៅមុខក្មួយនិយាយ

កៈ អត់អីទេពូអាចប្រាប់ក៏បានដែរពូចង់និយាយថា
កាលពីតូចពូមានធ្លាប់ជួបការលំបាកអីហើយជំនាន់ ពលពតនឹងជំនាន់លុនណុល
ពូធ្លាប់ជួបបញ្ហាលំបាកអីគេខ្លះដែរចឹងហាសពូ?

ខៈ
បាទ!!បាទនឹងពីសម័យមុនពីសម័យសង្គមរាស្ត្រនិយមខ្ញុំមានការលំបាកជាលក្ខណៈគ្រួសារ ពីព្រោះគ្រួសាររបស់ខ្ញុំនឹងជាគ្រួសារអ្នកក្រីក្រជាអ្នកធ្វើស្រែណាស់ក្មួយណាស់

កៈ បាទ!!ពូបាទ?

ខៈ
ដល់ចឹងឪពុកម្ដាយរបស់យើងមានជីវភាពលក្ខណៈទន់ខ្សោយចឹងយើងរៀនសូត្រនោះមិនបានពេញ លេញទេជួយការងារឪពុកម្ដាយ
ឧទាហរណ៍ថាឪឡូវនឹងចូលកងចឹងយើងរៀនបានតែដំបូងតែដល់មួយ
ខែទៅពីរខែស្រូវទុំចឹងជួយច្រូតម្ដាយដល់ខែវស្សាចឹងជួយភ្ជួរ ជួយរាស់ជួយស្ទូង
ជួយដកចឹងទៅណាស់

កៈ បាទ!!ពូបាទ?

ខៈ ហើយដល់មកសម័យពលពតខ្ញុំពិបាកចិត្តពិបាកចិត្តនៅកងចល័តនឹង
លឺដំណឹងគេថាចាប់ឪពុកដាក់
ពន្ធនាគារនឹងខ្ញុំពិបាកចិត្តណាស់ពិបាកខ្លាំងមែនទែនហាសក្មួយ

កៈ បាទ!!ពូបាទ?

ខៈ តែយើងមិនហ៊ានៅសម័យនោះយើងមិនហ៊ានតវ៉ា
មិនហ៊ាននិយាយមិនហ៊ានថានឹកអាណិតឪពុកគេ យកទៅដាក់រហូតទាល់តែគាត់ស្លាប់
គាត់ស្លាប់ទៅនឹងខ្ញុំកាន់តែពិបាកចិត្តថែមទៀតហើយណាស់ក្មួយណាស់

កៈ ប៉ុន្តែ?

ខៈ កាន់តែពិបាកចិត្តថែមទៀត
ហើយម៉្យាងទៀតបានឃើញម្ដាយនឹងគេអោយទៅភ្ជួរដូចមនុស្សប្រុសចឹង
ធ្វើបាប់គាត់ពីព្រោះគាត់នឹងជាប្រពន្ធទាហ៊ានចឹងកាលពីជំនាន់ណុងហាស

កៈ បាទ!!ពូបាទ?

ខៈ គេធ្វើបាបអោយគេភ្លូវដូចមនុស្សប្រុសចឹងហើយយើងក៏ពិបាកចិត្ត

កៈ ចុះ?

ខៈ យើងពិបាកចិត្តខ្លាំងមែនទែន

កៈ ចុះពូពេលដែរជំនាន់ពលពតនឹងគេអោយពូទៅធ្វើអីគេថដែរទៅ?

ខៈ  នឹងនៅក្នុងកងចល័តក្មួយនៅក្នុងកងចល័តនឹងគេអោយធ្វើស្រែគេអោយទៅដឹកជញ្ជូនស្រូវ អង្ករអីនឹងយកទៅអោយពួកកងចល័តនឹងហាសក្មួយ

កៈ បាទ!!ពូដូចជាពេលណុងគេជំលាសពូទៅណាដែរទៅពូ?

ខៈ អើរជំនាន់នោះជំលាសកាលណោះពីមុនខ្ញុំនៅភូមិស្វាយតានី ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង

កៈ បាទ!!ពូ?

ខៈ

ដល់ក្រោយមកគេជំលាសអោយគ្រួសាររបស់ខ្ញុំទៅនៅខាងស្រុកទៅនៅខាងភូមិតាហ៊ុយហាសក្មួយ

កៈ បាទ!!ពូ?

ខៈ ទៅនៅភូមិតាហ៊ុយ ឃុំកំពង់ប្រសាទ ស្រុកពាមចរ ខេត្តព្រៃវែងដូចគ្នា គ្រាន់តែនៅតាមដងទន្លេ

កៈ ភូមិនឹងនៅជិតគ្នាមែនពូ?

ខៈ ឆ្ងាយក្មួយឆ្ងាយគេជំលាសខ្ញុំទៅស្រុកបាភ្នំ មួយគេជំលាសខ្ញុំទៅនៅស្រុកពាមចរនៅជាប់ព្រំប្រទល់ វៀតណាមហោស

កៈ អ៊ូ!!ឆ្ងាយដែរពូ?

ខៈ បាទ!!គេជំលាសឆ្ងាយ

កៈ អ៎ូ!!ចឹងពេលដែរពុគេជំលាសដូរកន្លែងចឹងពូដូរការងារដែរណាពូណា?

ខៈ បាទ!!ដូរដែរក្មួយដូរដែរ

កៈ ចុះគេអោយធ្វើការងារអីថ្មីដែរពូ?

ខៈ បាទ!!ការងារថ្មីអានឹងនៅក្នុងកងចល័តដដែលប៉ុន្តែគ្រាន់តែថាប្តូរមូលដ្ឋានហាសក្មួយ

កៈ បាទ!!ពូបាទ?

ខៈ
ប្តូរមូលដ្ឋាននៅក្នុងកងចល័តនៅលើកទំនប់លើកដីអីទៅលើកទំនប់នឹងគេហៅទំនប់ពីងពង់នឹង

កៈ បាទ!!ពូបាទ?

ខៈ យើងលើកដីធ្វើទំនប់នៅកន្លែងនឹងក្មួយ

កៈ បាទ!!ប៉ុន្តែគេចល័តពូតែប៉ុណ្ណឹងតើហីពូ?

ខៈ បាទ!!

កៈ គេអត់មានចល័តពូទៅកន្លែងណាផ្សេងទៀតណាហីពូ?

ខៈ អត់មានទេក្មួយគ្រួសារខ្ញុំទៅតែប៉ុណ្ណឹងតែនៅកន្លែងនឹង

កៈ អ៎ូ!!ចុះបងប្អូនពូវិញ?

ខៈ បងប្អូនរបស់ខ្ញុំកាលណុងវានៅសុទ្ធតែជានៅវ័យកុមារដែរ នឹងនៅវ័យយុវជន
ហើយអាអ្នកដែរនៅ ពេញៗវ័យនឹងអើរនៅសម័យមុននោះអាបន្ទាប់ខ្ញុំនឹងវាស្លាប់

កៈ បាទ!!ពូបាទ?

ខៈ បាទ!!វាធ្វើទាហ៊ានស្លាប់ ហើយដល់មកអាបន្ទាប់ទៀតវាទៅពលករស្លាប់

កៈ បាទ!!ពូបាទ?

ខ៖ បាទ!!វាទៅពលករស្លាប់
បន្ទាប់ខ្ញុំនឹងអស់ពិរហើយមកដល់ប្អូនស្រីនឹងវាមានជំងឺផ្ទាល់ខ្លួននឹង
វាមានជំងឺផ្ទាល់ខ្លួននឹងប្អូនស្រីគិតទៅវាស្លាប់អស់3នាក់នឹង

ក៖ បាទ!!ពូបាទ?

ខ៖ អើរវាស្លាប់នៅសមរភូមិនឹងអស់ពីរនាក់ហើយតែស្លាប់នៅជំងឺម្នាក់នឹងណាស់ក្មួយ

ក៖ បាទ!!ពូបាទ ចុះពូគិតថាពូមានជំនាញអីដែរពូចេះស្ទាត់ជំនាញទេពូ?

ខ៖ ខ្ញុំពីមុនមករហូតមកទាល់ឥឡូវនឹងជំនាញខ្ញុំមានតែខាងនេះទេក្មួយមានតែខាងអាចារ្យ
ឥឡូវនឹងសព្វ ថ្ងៃខ្ញុំចាប់អាជីពជាអាចារ្យវេលាណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ចាប់ជាអាចារ្យការណាស់ក្មួយជាអាចារ្យការ
នឹងអាចារ្យបុណ្យអីនឹងបងប្អូនចេះតែមកពឹងពរកយើង
ទៅធ្វើកិច្ចអោយកូនក្មួយអ្នកនៅក្នុងស្រុកក្នុងភូមិអីចឹងហាស
ខ្ញុំតាំងពីនៅក្នុងស្រុកកំណើតមកម្ល៉េស

ក៖ អូ៎!!បាទពូបាទ?

ខ៖
ខ្ញុំធ្លាប់ដើរទៅធ្វើមហាជាមួយអាចារ្យចឹងទៅយូរៗទៅខ្ញុំនឹងអាចនឹងចេះដឹងជាមួយនឹងគាត់នឹងអាច
នឹងយល់អាចនឹងធ្វើអាចារ្យវេលាឥឡូវនឹងធ្វើអាចារ្យវេលាក្មួយចាប់អាជីពជាអាចារ្យវេលា

ក៖ អូ៎!!ពូអាចធ្វើបានណាពូ?

ខ៖ បាទ!!អាចធ្វើបាន

ក៖ បាទ!!ចុះពូគិតថាឪពុកម្តាយរបស់ពូធ្លាប់បង្រៀនពីជំនាញអីផ្សេងទៅពូដែរទេ?

ខ៖ ឪពុកម្តាយរបស់ខ្ញុំកំរិតវប្បធម៌គាត់នៅទាបដែរនឹង
ទាបដល់ពេលចឹងអត់មានជំនាញអីបង្រៀនអោយ ខ្ញុំបានចេះដឹងជ្រៅជ្រះទេណាស់

ក៖ ប៉ុន្តែលក្ខណះជំនាញលក្ខណះកូរស្ករ វេញល្អី ធ្វើផ្តៅ ធ្វើកន្ទេលធ្វើអីនឹងពូចេះទេ?

ខ៖ ខ្ញុំអត់ចេះទេក្មួយចេះតែធ្វើស្រែនឹងតែម្តង

ក៖ អូ៎!!បាទពូបាទ?

ខ៖ បើលក្ខណះធ្វើស្រែឪពុកម្តាយរបស់ខ្ញុំបង្ហាត់បង្រៀនខ្ញុំធ្វើស្រែ ធ្វើចំការភ្ជួររាស់ស្ទូងដកតែប៉ុណ្ណឹង ច្រូតកាត់នឹងក្មួយមានតែប៉ុណ្ណឹង

ក៖
ចុះពូគិតថាផ្ទះរបស់ពូមានលក្ខណះបែបណាតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូ?

ខ៖ តាំងពីដំបូងតាំងពីខ្ញុំកើតដឹងក្តីមកផ្ទះឪពុកម្តាយរបស់ខ្ញុំជាផ្ទះលក្ខណះផ្ទះសសរឈើណាស់

ក៖ បាទ!!ពូបាទ?

ខ៖ ប្រកស្លឹកត្នោត ជញ្ជាំងក៏ស្លឹកត្នោត
ដល់ក្រោយមកទៅឃើញឪពុកម្តាយរបស់ខ្ញុំវារៀងគ្រាន់បើទៅ
ក៏ទិញឈើអាលក្ខណះឈើល្អធ្វើបានផ្ទះពីរខ្នងក្មួយ ខ្មែរយើងគេហៅផ្ទះកាតាំងហាស

ក៖ បាទ!!ពូបាទ?

ខ៖ ធ្វើផ្ទះកាតាំងពីរខ្នងជាលក្ខណះផ្ទះឈើល្អ
នឹងទិញផ្ទះចាស់គេមកធ្វើប៉ុន្តែធ្វើផ្ទះឈើល្អមកធ្វើផ្ទះ ហាសក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ពីមុនយើងធ្វើឈើដូចថាកាប់ដើមឈើដើមព្រៃរបស់ដូនតាយើងដូចជាដើមត្នោត
ដើមស្តៅរឺជាដើមស្អីៗៗនឹងយកមកធ្វើទៅណាស់

ក៖ បាទ!!ពូបាទ?

ខ៖ ដល់ហើយពីនឹងទៅយើងទិញឪពុកម្តាយបានហូបចុកគ្រាន់បើជីវភាពរៀងគ្រាន់បើទៅ
គាត់លក់ក្របីលក់អីទិញបានផ្ទះរៀងគួរសម បានបានធ្វើផ្ទះកាតាំងបានពីរខ្នង

ក៖ បាទ!!ពូបាទ?

ខ៖ បានពីរខ្ទងប៉ុន្តែនៅតែប្រកស្លឹកបានជារយះបានប្រហែលជា3-4ឆ្នាំបានគាត់រកបានក្រាន់បើទៅបាន គាត់ទិញស័ង្កសីទៅបានប្រកនឹងហាសក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ប៉ុន្តែជញ្ជាំងនឹងជាជញ្ជាំងស្លឹកដដែលទេ

ក៖ បាទ!!ចុះពូគិតថាផ្ទះរបស់ពូនឹងនរណាគេជាអ្នកជួសជុលជាអ្នកសាងសងដែរពូ?

ខ៖ អើរផ្ទះនឹងគឺឪពុកម្ដាយរបស់ខ្ញុំអ្នកធ្វើតែម្ដងនឹង ជួលជាងគេជាអ្នកធ្វើណាស់ក្មួយ

ក៖ បាទ!!ប៉ុន្តែពូចេះធ្វើផ្ទះទេ?

ខ៖ ខ្ញុំអត់ចេះទេក្មួយអត់ចេះទេ

ក៖ បាទ!!ចុះពូមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសារពូចេះលេងឧបករណ៍ភ្លេងដែរទេ?

ខ៖ អើរឧបករណ៍ភ្លេងនិយាយមកគឺថាឪពុករបស់ខ្ញុំនឹងគឺជាអ្នកលេងភ្លេងប្រពៃណីដែរក្មួយ

ក៖ អូ៎!!ប៉ុន្តែគាត់លេងខាងផ្នែកអីគេដែរពូ?

ខ៖ លេងខាងផ្នែកប្រពៃណីលេងខាងភ្លេងការណាស់ក្មួយ

ក៖ អូ៎!!បាទពូបាទ?

ខ៖ លេងភ្លេងការនឹង

ក៖ អូ៎!!បាទ?

ខ៖
ហើយបន្ទាប់ពីគាត់មកនឹងខ្ញុំក៏បានចេះបន្តបន្ទាប់មកខ្ញុំក៏មានដុងខាងផ្នែកសិល្បិ៍នឹងខ្លះដែរក្មួយ ខ្ញុំនឹងហាស

ក៖ អូ៎!!ប៉ុន្តែពូក៏ចេះដែរ?

ខ៖ បាទ!!

ក៖ អូ៎!!ចឹងពូចេះច្រៀងអត់ពូ?

ខ៖
ខ្ញុំកាលពីមុនមកការនៅពោពេញវ៉ៃយលេងការនៅឆ្នាំលេងយើងពីឆ្នាំប៉ែតជាងហាសក្មួយប្រហែលជា ឆ្នាំ1984-1985នឹងហាសក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ មានលោកគ្រូម្នាក់នឹងគាត់មកបង្ហាត់ល្ខោនបាសាក់

ក៖ បាទ!!ពូបាទ?

ខ៖ មកបង្ហាត់ល្ខោនបាសាក់
ខ្ញុំក៏ចូលលេងល្ខោនបាសាក់នឹងជាមួយនឹងគ្រូនឹងបានរយះពេល2ឆ្នាំ

ក៖ បាទ!!ពូបាទ?

ខ៖ បាទៗៗ!!

ក៖ ចុះពូគិតថាពូចូលចិត្តពិសារម្ហូបអីគេដែរពូនៅក្នុងជីវិតរបស់ពូហាស?

ខ៖ ខ្ញុំនិយាយពីម្ហូបហូបនឹងខ្ញុំអត់មានប្រកាន់មុខណាទេក្មួយអោយតែមាន
ខ្ញុំហូបបានទាំងអស់តាំងពី
សាច់ជ្រូករឺមួយក៏ត្រីនិយាយរួមមកម្ហូបអាហារអោយតែយើងហូបបានយើងហូប

ក៖ អ៊ូ!!ចឹងហោសពូ?

ខ៖ បាទ!!គ្មានរើសម្ហូបមុខណាទេណាស់ហូបបានទូទៅ

ក៖ ចុះពូគិតថាល្បែងប្រជាប្រិយ៍អីដែរពូគិតថាពូចូលចិត្តលេងតាំងពីក្មេងហាសពូ?

ខ៖
ពីក្មេងដូចខ្ញុំនិយាយប្រាប់ក្មួយចឹងពីព្រោះខ្ញុំជាធាតុសិល្បះជាពិដាចជីដូនជីតាខ្ញុំឪពុកម្តាយខ្ញុំនឹង

ក៖ បាទ!!

ខ៖ ជីដូនជីតារបស់ខ្ញុំនឹងក៏គាត់ខាងភ្លេងប្រពៃណីដែរខាងភ្លេងខ្មែរយើងនឹង

ក៖ បាទ!!ពូបាទ?

ខ៖
ហើយខាងឪពុកខ្ញុំនឹងគាត់ក៏ជាប់នៅខាងនឹងដែរមកខ្ញុំនឹងក៏មានដុងខាងសិល្បះនឹងខ្លះៗៗ
វាចឹង

ក៖ អ្ហ៎!!បាទពូបាទ
ចុះពូគិតថាជីវិតរបស់ពូនឹងមានការផ្លាស់ប្តូរអីគេខ្លះដែរពូពីក្មេងមកដល់ពេលនេះហាស?

ខ៖ បាទ!!ពីក្មេងរហូតមកដល់ពេលនេះហាសមានការផ្លាស់ប្តូរហើយក្មួយ
ពីមុនមកដូចថាយើងមានវ័យ នៅក្មេងហើយកំលាំងយើងក៏នៅពេញលេញចឹងហាស
ហើយការរស់នៅរបស់យើងនឹងក៏មានលក្ខណះ ផ្សេងចឹងណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖
តែមកដល់ឥឡូវនឹងដូចថាវាប្តូរវ័យទៅវ័យយើងក៏រៀងចាស់ការផ្លាស់ប្តូរនឹងទៅតាមវ័យ
ណាស់

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!ផ្លាស់ប្តូរតាមវ័យបាទខុសប្លែកពីមុន

ក៖ ចុះពូគិតថាពេលណាដែរពូសប្បាយជាងគេនៅក្នុងឆាកជីវិតរបស់ពូដែរហាសពូ?

ខ៖
ខ្ញុំសប្បាយនៅក្នុងលក្ខណះរបស់ខ្ញុំបើអោយចិត្តសប្បាយវិញគ្មានអ្វីអោយមានសុភមង្គល
នៅក្នុង ក្រុមគ្រួសារដែររឺមួយក៏យើងនៅខាង
ឧទាហាករណ៍ថាឥឡូវនឹងយើងនៅខាងប្រជាប្រិយ៍វិញហាស

ក៖ បាទ!!ពូបាទ?

ខ៖ យើងចូលចិត្តដើរលេងល្ខោនបាសាក់អីចឹងទៅ
រឺមួយក៏យើងទៅលេងសៃយ៉ាមអីចឹងទៅ ដូចថាតាមជំនាញអ្វីដែរខ្ញុំចេះហាស

ក៖ បាទ!!ពូបាទ?

ខ៖ អានឹងវាមានលក្ខណះសប្បាយនៅក្នុងចិត្តរួមលេងជាមួយអ្នកដែរនៅជិតចឹងទៅក្មួយ

ក៖ បាទ!!ពូចុះពុគិតថាបើសិនដូចជាកាលពីក្មេងហាស
ពូធ្លាប់មានក្តីស្រម៉ៃថាពេលដែរពូធំឡើងនឹងពូ ចង់ធ្វើអីដែរទេពូ?

ខ៖ ខ្ញុំពីក្មេងមកដូចថាខ្ញុំប្រាថ្នាចិត្តរបស់ខ្ញុំនឹងខ្ញុំស្រលាញ់ខាងជាសិល្បះនឹងតែម្តង

ក៖ បាទ!!ពូបាទ?

ខ៖ តាំងពូក្មេងនឹងមក

ក៖ ចុះពូគិតថា?

ខ៖
ចូលចិត្តតែលេងឧបករណ៍ក្មេងៗៗគ្នាឯងនឹងលេងភ្លេងឧបករណ៍ជាភ្លេងប្រពៃណីខ្មែរនឹង
តែម្តងនឹង ទៅវាលទៅមើលឃ្វាលក្របីក៏ដោយឃ្វាលអីក៏ដោយ
នាំគ្នាលេងតែភ្លេងអាប្រពៃណីនឹងក្មួយ

ក៖ អ៊ូ!!បាទពូ?

ខ៖
ឪពុកម្តាយជីដូនជីតារបស់យើងនឹងយើងកើតមកឃើញតែពួកគាត់ធ្វើអាចឹងៗៗហាសណា
ស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ បាទ!!គាត់រៀនអាចឹងៗៗ

ក៖ ចុះពូគិតថាបើសិនជាចង់អោយពូផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗ
តើពូចង់ផ្តែផ្តាំអីទៅពួកគាត់ដែរពូ?

ខ៖ ខ្ញុំសុំផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយពីព្រោះយើងជាខ្មែរ
សុំកូនចៅជំនាន់ក្រោយៗៗនឹងកុំភ្លើតភ្លើន យកប្រពៃណីរបស់គេបំពាក់បំពនអោយខ្លួន
សូមយើងគិតពីអរិយ៍ធម៍របស់ខ្លួនគិតពីរបាំប្រជាប្រិយ៍
ជាភ្លេងប្រពៃណីលក្ខណះជាខ្មែរសុំកូនខ្មែរជំនាន់ក្រោយនឹងកុំអោយបាត់បង់អោយសោះ

ក៖ បាទ!!ពូបាទ?

ខ៖ សូមរក្សាអោយបានគង់វង្សស្ថិតស្ថេរទៅមុខ
កុំអោយកូនចៅជំនាន់ក្រោយនឹងអាចភ្លេចភ្លាំងដោយ ប្រការណាមួយអាចនឹងដឹងបាន

ក៖ បាទពូបាទ?

ខ៖ ដល់ពេលចឹងមានក្មួយៗដែរបានមកសំភាសន៍ខ្ញុំហាស
ខ្ញុំសុំផ្តាំខ្មែរជំនាន់ក្រោយនឹងអោយ គិតគូអំពីអាបញ្ញាអារិយ្យធិមរបស់ខ្លួន
អំពីប្រពៃណីរបស់ខ្លួន ស្លៀកពាក់ក៏ដោយអោយមានលក្ខណះជា
របៀបទំនៀមទំលាប់របស់ខ្មែរណាស់ក្មួយ

ក៖ បាទ!!ពូបាទ?

ខ៖ ខ្ញុំសូមផ្តាំប៉ុណ្ណឹង

ក៖
ចុះបើសិនជាចង់អោយពួកកូនចៅជំនាន់ក្រោយជៀសវៀងរឺមួយក៏ការជៀសផុតពីអីមួយ
ចង់អោយពួកគាត់ជៀសពីអ្វីខ្លះដែរទៅពូ ដូចជាអំពើមួយដែរអត់ល្អចឹងហាស?

ខ៖ អំពើដែរអត់ល្អខ្ញុំបានឃើញជាក់ស្តែងសព្វថ្ងៃនេះក្មួយ
ឃើញទៅជាក់ស្តែងហើយនឹងអាចនិយាយទៅ
ចុះមនុស្សមិនអោយខុសណាស់ក្មួយណាស់

ក៖ បាទ!!ពូ?

ខ៖ សុំកូនចៅជំនាន់ក្រោយទាំងអស់ជៀសវៀងពីថ្នាំញៀននេះកុំប្រព្រឹត្តអោយសោះ

ក៖ បាទ!!ពូបាទ?

ខ៖ ក្មួយៗកូនចៅទាំងអស់បើប្រព្រឹត្តថ្នាំញៀនដូចបំផ្លាញជីវិតខ្លួនឯងចោលចឹង
មិនអាចនឹងមានសុភមង្គលទៅថ្ងៃក្រោយទេណាកូនណាស់

ក៖ បាទ!!ពូបាទត្រូវពូ?

ខ៖ ខ្ញុំសូមផ្តាំប៉ុណ្ណឹង

កៈ
បាទចឹងប្រហែលជាចុងក្រោយខ្ញុំសូមអរគុណច្រើនពូដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់ពូ ចឹងហាសពូ?

ខៈ បាទ!!

កៈ ចឹងខ្ញុំអាចសុំបញ្ជាក់ទីតាំងម្តងទៀតបានទេពូដូចជានៅភូមិអីគេដែរនៅនឹងពូ?

ខៈ ខ្ញុំនៅបច្ចុប្បន្ននឹងហោសក្មួយហោស?

កៈ បាទ!!ពូបាទ?

ខៈ បាទ!!ខ្ញុំនៅភូមិព្រែកថ្លឹង

កៈ ភូមិព្រែកថ្លឹង?

ខៈ សង្កាត់ជើងឯក ខ័ណ្ឌដង្កោ នៅរាជធានីភ្នំពេញហាសក្មួយ

កៈ អូ៎ៗ!!បាទពូបាទចឹងអរគុណច្រើនពូដែរបានអោយខ្ញុំសំភាសន៍ណាស់ពូ?

ខៈ បាទអរគុណក្មួយ

កៈ បាទ!!អរគុណច្រើនពូ៕៕៕